
អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

រឿងទីក្រុងនិងភូមិ


The Country Mouse And The City Mouse

កែសម្រួលដោយ TukTuk
រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន




កាលពីព្រេងនាយ មានកណ្តុរពីរក្បាលជាសម្លាញ់នឹងគ្នា។
ថ្ងៃមួយកណ្តុរទីក្រុងបានមកលេងកណ្តុរស្រុកស្រែ។
កណ្តុរស្រុកស្រែពិតជាសប្បាយចិត្តខ្លាំងណាស់ ហើយបានរៀបចំម្ហូបអាហារសាមញ្ញបែបស្រុកស្រែ ដើម្បីទទួលកណ្តុរទីក្រុង។







«ហូបឱ្យឆ្អែតទៅសម្លាញ់ កុំខ្លាចចិត្តខ្ញុំអី»។ ម្ហូបមានទឹកត្រឿង ហហ្មុក (អាម៉ុក) បាយនិងផ្លែឈើជាដើម។ កណ្ដុរទីក្រុងបានឃើញហើយក៏និយាយ «អូ ព្រះអើយ! តើឯងចូលចិត្តហូបអាហារសាមញ្ញបែបហ្នឹង? ហេតុអ្វីបានជាឯងមិនសាកទៅទីក្រុងម្ដងមើល? ព្រោះទីនោះមានអាហារឆ្ងាញ់ៗច្រើនណាស់»។





កណ្តុរស្រុកស្រែបានសម្រេចចិត្តទៅលេងទីក្រុងម្តង។
ទីក្រុងពិតជាធំខ្លាំងណាស់ ហើយមានរ៉ឺម៉កកង់បីពាសពេញហ្នឹងតែម្តង «ឆាប់ទ្បើងៗ
វាមានគ្រោះថ្នាក់ណាស់ កុំដើរយឺតពេក» កណ្តុរទីក្រុងនិយាយ។
កណ្តុរស្រុកស្រែក៏ដើរតាមផ្លូវទាំងអារម្មណ៍ភ័យខ្លាចនិងស្រឡាំងកាំង។







កណ្តុរទីក្រុងនិយាយ «ពួកយើងបានមកដល់ផ្ទះដែលខ្ញុំរស់នៅហើយ»។
កណ្តុរស្រុកស្រែបានចូលទៅក្នុងផ្ទះបាយក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំងតែម្តង។
នៅលើតុអាហារមានសុទ្ធតែម្ហូបអាហារប្លែកៗ ដែលវាមិនដែលបានឃើញពីមុនមកនោះទេ។
កណ្តុរស្រុកស្រែលាន់មាត់ «អូ! ពិតជាអស្ចារ្យខ្លាំងណាស់»។







កណ្តុរទីក្រុងនិយាយ «ហូបឱ្យច្រើនៗទៅសម្លាញ់ កុំក្រែងចិត្តអីណា»។
កណ្តុរទាំងពីរកំពុងហូបសុខៗ ស្រាប់តែឮស្នូរជើងនរណាម្នាក់បានដើរចូលមក។
កណ្តុរទីក្រុងនិយាយ «ពួកយើងជួបអាសន្នហើយ តស់! ទៅរកកន្លែងលាក់ខ្លួន
សិន»។


Tuk Tuk





«ពួកយើងត្រូវលាក់ខ្លួនឱ្យស្ងៀមស្ងាត់រហូតដល់មនុស្សចេញសិន ប្រសិនបើមិន
ដូច្នេះទេ ពួកយើងនឹងត្រូវគេដេញចាប់ហើយ»។
«មនុស្សចេញហើយ ពួកយើងហូបអាហារបន្ត!»។







កណ្តុរទាំងពីរបានឡើងទៅលើតុបាយម្តងទៀត។
បន្ទាប់មក ពួកគេបានឮស្នូរជើងមនុស្សចូលមកទៀតហើយ។
«ពួកយើងជួបអាសន្នទៀតហើយ តស់! ទៅលាក់ខ្លួនម្តងទៀតសិន!»។
ពួកគេទាំងពីរពិតជាឃ្លានខ្លាំងណាស់ តើពួកគេត្រូវលាក់ខ្លួនបែបនេះប៉ុន្មានដងទៀត?
កណ្តុរស្រុកស្រែភ័យខ្លាចនិងមិនសូវចិត្តនោះទេ។






«ឥឡូវនេះយើងអាចចេញបានហើយ ដូច្នេះឯងហូបបានតាមសប្បាយ
ចង់ហូបប៉ុណ្ណាក៏បានដែរ»។
«កុំបារម្ភណ៍អីណា ខ្ញុំនឹងហូបវាឱ្យច្រើនៗតែម្តង»។
ប៉ុន្តែភ្លាមៗនោះ កណ្តុរស្រុកស្រែអស់កម្លាំងជាខ្លាំង។





កណ្តុរទីក្រុងសួរ «ហេតុអ្វីបានជាសម្លាញ់ឆាប់ត្រលប់ទៅផ្ទះម្ល៉េះ តើអាហារមិនឆ្ងាញ់ឬហូបមិនឆ្អែត?»។
«ខ្ញុំចង់រស់នៅស្រុកស្រែវិញ ទោះបីជាពួកយើងមិនមានម្ហូបអាហារល្អពិសេសក៏ពិតមែន តែពួកយើងអាចហូបបានដោយមិនមានភាពភ័យខ្លាច»។ កណ្តុរស្រុកស្រែបានលាសម្លាញ់របស់វា «លាហើយសម្លាញ់ខ្ញុំត្រលប់ទៅផ្ទះស្រុកស្រែវិញហើយ»។
ពួកគេទាំងពីររស់នៅមានក្តីសុខដូចគ្នា គ្រាន់តែតាមរបៀបផ្សេងគ្នាប៉ុណ្ណោះ។





កណ្តារទីក្រុងនិងកណ្តារស្រុកតំស្រែ

កែសម្រួលដោយ TukTuk

រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary